ប៉ារីសថ្ងៃទី ១5 ខែកុម្ភៈ ឆ្នាំ២០១៣

# តុលាការអន្តរជាតិឬ ICC

## ១/តើអ្វីជាតុលាការអន្តរជាតិ?

តុលាការអន្តរជាតិដែលភាសាអង់គ្លេសហៅថា ICC (International-Criminel-cour)ជាភាសាបារាំង CPI (Cour Pénale Internationale) ជាតុលាការអន្តរជាតិអចិន្ត្រៃទទួលបន្ទុកកាត់ទោសជនជាប់ចោទពីបទឧក្រិដ្ឋកម្មធ្ងន់ៗបំផុតដូចជាៈ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម, និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ តុលាការអន្តរជាតិត្រូវបានបង្កើតឡើងបន្ទាប់ពីមានការប្រជុំភ្នាក់ងារអង្គទូតនៃអង្គការសហប្រជាជាតិ ។ លក្ខន្តិកៈរ៉ូម (Statut de Rome) ដែលគ្រោងសម្រាប់បង្កើតតុលាការអន្តរជាតិត្រូវបានចុះហត្ថលេខានៅថ្ងៃទី ១៧ កក្កដា១៩៩៨ ហើយតុលាការអន្តរជាតិនេះត្រូវបានបង្កើតជាស្ថាពរនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ ជាថ្ងៃដែលគេបានបញ្ចូលលក្ខន្តិកៈរ៉ូមជាធរមាន(en vigueur) ។ តុលាការអន្តជាតិមានតួនាទីនិងសិទ្ធិកាត់ទោសតែឧក្រិដ្ឋកម្មណាដែលបានប្រព្រឹត្តិក្រោយថ្ងៃដែលគេបានបញ្ចូលលក្ខន្តិកៈរ៉ូមជាធរមាន ។ ទីស្នាក់ការនៃតុលាការអន្តរជាតិស្ថិតនៅឡាអេ ប្រទេសហូឡង់ ប៉ុន្តែការកាត់ទោសអាចប្រព្រឹត្តិទៅគ្រប់ទីកន្លែង ។

នៅខែមេសា ឆ្នាំ២០១២, ប្រទេសចំនួន១២១ នៃ១៩៣ប្រទេសដែលជាសមាជិកអង្គការសហប្រជាជាតិបានអោយសច្ចានុម័តិលើលក្ខន្តិកៈរ៉ូម ហើយទទួលស្គាល់អាជ្ញានៃតុលាការអន្តរជាតិ ក្នុងនោះមាន សហភាពសូវៀត, អាមេរិកដែលបានចុះហត្ថលេខាលើលក្ខន្តិកៈរ៉ូម តែមិនបានបានអោយសច្ចានុម័តិ ។ ឯប្រទេសចិន និងប្រទេសឥណ្ឌាមិនបានចុះហត្ថលេខាទេ ហើយបានទិតៀនជាខ្លាំងលើអាជ្ញានៃតុលាការនេះ ។ តាមការអនុវត្តន៍ជាក់ស្តែង តុលាការអន្តរជាតិអាចកាត់ទោសតែជនជាប់ចោទណាដែលរស់នៅក្នុងប្រទេសជាសមាជិក ឬក៏ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិក្នុងប្រទេសជាសមាជិកឬក៏ករណីនេះត្រូវបានបញ្ជូនមកដោយអង្គការសហប្រជាជាតិ ។ តុលាការអន្តរជាតិត្រូវបានរៀបចំឡើងដើម្បីបំពេញបន្ថែមលើប្រពន្ធ័តុលាការជាតិប៉ុណ្ណោះ ។ តុលាការអន្តរជាតិមិនអាចបំពេញតួនាទីរបស់ខ្លួនប្រសិនជាតុលាការជាតិគ្មានចេតនា ឬគ្មានសមត្ថភាពក្នុងការកាត់ទោសឧក្រិដ្ឋកម្មនោះ ។ ដូច្នេះដើម គំនិតនៃការស៊ើបអង្កេតនិងការកាត់ទោសគឺជាឯកសិទ្ធិនៃប្រទេសនិមួយៗ ។

រហូតមកដល់សព្វថ្ងៃនេះតុលាការអន្តរជាតិបានបើកនីតិក្រម(Procédure)លើ៧ករណីក្នុង១៨ករណី ។ ករណីទាំងនេះទាក់ទងនឹងឧក្រិដ្ឋកម្មនៅទ្វីបអាហ្វ្រិកទាំងអស់ មានៈ អូហ្គាំងដា(Ouganda), សាធារណរដ្ឋប្រជាធិបតេយ្យ កុងហ្គូ(la République démocratique du Congo), សាធារណរដ្ឋអាហ្វ្រិកកណ្តាល(République de Centrafrique), ដារហ្វួ (Darfour, Soudan), សាធារណរដ្ឋ គិនញ៉ា(République du Kenya), នៅលីប៊ី(Libye) និងនៅ កូឌីវ័រ(Côte d'Ivoire) ។ ហើយថ្មីៗនេះតុលាការ កំពុងតែពិនិត្យលើករណី អាល-អាសាដ(Al-Asad) នៅស៊ីរី(Syrie) ។ តុលាការបានចោទប្រកាន់លើមនុស្សចំនួន១៦នាក់ ដែល៧នាក់គេចខ្លួន, ២នាក់ស្លាប់, ៤នាក់ចាប់ខ្លួន និង៣នាក់បានមកបង្ហាញខ្លួនដោយខ្លួនឯងនៅចំពោះមុខតុលាការ ។ ក្តីទីមួយនៃតុលាការអន្តរជាតិចាប់ផ្តើមនៅថ្ងៃទី ២៩ មករា ឆ្នាំ២០០៩, ទាក់ទងនឹងជនជាតិកង់ហ្គូល, តូម៉ាសឡូបង់ហ្គា, (Thomas Lubanga) ចោទពីបទឧក្រិដ្ឋកម្មសង្គ្រាម ។ នៅថ្ងៃ១៤មិនា ២០១២ តូម៉ាសឡូបង់ហ្គាបានត្រូវតុលាការទទួល ស្គាល់ថា បានប្រព្រឹត្តិឧក្រិដ្ឋកម្មសង្គ្រាម ។ នេះគឺជាការកាត់ទោសលើកទីមួយរបស់តុលាការអន្តជាតិ ។

## ២/កម្មវត្ថុ

តុលាការអន្តរជាតិគឺជាស្ថាប័នអចិន្ត្រៃទទួលបន្ទុកក្នុងការពង្រឹងនិងការពារអន្តរសិទ្ធិ(Droit international) ។ ដូចគ្នានឹងតុលាការយុត្តិធម៌អន្តរជាតិ(Cour internationale de justice), តួនាទីនៃតុលាការអន្តរជាតិ កាត់ទោសបានតែបុគ្គលដែលបានប្រព្រឹត្តិឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម, ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មឈ្លានពាន (ចាប់ពីខែមិថុនា ២០១០) តែមិនអាចកាត់ទោសប្រទេសមួយបានទេ ។

ដោយតម្កើងយុត្តាធិការអចិន្ត្រៃនិងសកល តុលាការអន្តរជាតិមានទិសដៅធ្វើសកលភាវូបនិយកម្មសិទ្ធិមនុស្ស និងអន្តរសិទ្ធិមនុស្សធម៌ (Droit international humanitaire) ។ តុលាការអន្តរជាតិក៏មានកម្មវត្ថុ ជម្រុញអោយអ្នកនយោបាយមានការទទួលខុសត្រូវចំពោះអ្វីដែលខ្លួនប្រព្រឹត្តិ ។ ដូច្នេះតុលាការអន្តរជាតិមានតួនាទីពីរសំខាន់ៗ: ការពារនិងរារាំង (កម្លាច) ។

## ៣/ប្រវត្តិ

- នៅសតវត្សទី២០សហគមន៍អន្តរជាតិបានព្យាយាមអោយនិយមន័យថាអ្វីទៅឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

- នៅឆ្នាំ ១៨៧២, បន្ទាប់ពីមានសង្គ្រាម បារាំង-ព្រូស៊ីយាន (Franco-prussienne) ១៨៧០, លោក ហ្គូសស្តាវម៉ូនីញេ (Gustave Moynier,)ដែលជា សមាជិកនៃគណកម្មាធិការកាកបាទក្រហមអន្តជាតិ Comité international de la Croix-Rouge, បានផ្តើមគំនិតសុំបង្កើតអោយមានតុលាការសម្រាប់កាត់ទោសការរំលោភអន្តរសិទ្ធិមនុស្សធម៌ (Droit international humanitaire) ដែលកាលណោះតំណាងដោយ (Convention de Genève de 1864)ប៉ុន្តែគំនិតរបស់លោកពុំបានសម្រេចលទ្ធផលអ្វីទេ ។

- ក្រោយសង្គ្រាមលោកលើកទី១ សន្ធិសញ្ញាវែកសៃ (Traité de Versailles)ក្នុងមាត្រាទី២២៧ ចង់ជម្រុញមានការបង្កើតតុលាការអន្តរជាតិមួយដើម្បីកាត់ទោសលោក ហ្គីយោម២ (Guillaume II) ពីបទ "កំហុសដ៏ធ្ងន់ធ្ងរប្រឆាំងអន្តរសីលធម៌និងអាជ្ញានៃសន្ធិសញ្ញា(« *offense suprême contre la morale internationale et l'autorité sacrée des traités* ».) តែតុលាការនេះមិនបានចេញជារូបរាងអ្វីទេ ឯលោកហ្គីយោម២ (Guillaume II)បានរត់គៀសខ្លួនទៅរស់នៅប្រទេស Pays-Bas ដែលបដិសេធមិនព្រមប្រគល់រូបលោកមកវិញ ។ ម្តងទៀតនៅឆ្នាំ១៩៣៧ ក្នុងមហាសន្និបាតមួយក្រោមការដឹកនាំនៃសហប្រជាជាតិ (Société des Nations) បានព្យាយាមដាក់គំនិតនេះម្តងទៀត តែពុំបានលទ្ធផលអ្វីទេ ។

- ក្រោយសង្គ្រាមលោកលើកទី២ តុលាការអន្តរជាតិចំនួន២ត្រូវបានបង្កើតឡើងដើម្បីកាត់ទោសឧក្រិដ្ឋកម្មណាស៊ី ។

១ តុលាការនូរិមប៊ែក (Tribunal de Nuremberg) បង្កើតឡើងនៅថ្ងៃទី៨ ខែតុលា ឆ្នាំ១៩៤៥ ដោយសន្ធិសញ្ញាទីក្រុងឡុង ដែលបានបញ្ជាក់ពីអត្ថន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងសន្តិភាព, ឧក្រិដ្ឋកម្មសង្គ្រាម, និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

២ តុលាការតូក្យូ បង្កើតឡើងនៅថ្ងៃទី១៩ ខែមករា ឆ្នាំ ១៩៤៦ ។ នៅឆ្នាំ១៩៤៨, សភាអង្គការអន្តរជាតិទទួលស្គាល់ការចាំបាច់នៃការបង្កើតអោយមានយុត្តាធិការ(juridiction)អចិន្ត្រៃដែលមានសមត្ថភាពកាត់ទោសឧក្រិដ្ឋកម្មធ្ងន់ធ្ងរដូចដែលបានកើតឡើងក្នុងសង្គ្រាមលោកលើកទី២ ។

- នៅឆ្នាំ១៩៥០ គណកម្មការអន្តរសិទ្ធិបានរៀបចំលក្ខន្តិក:២ តែសង្គ្រាមត្រជាក់បានធ្វើអោយដំណើរការត្រូវអាកខានទៅវិញ ។

## ៤/តុលាការអន្តរជាតិបណ្តោះអាសន្ន

ដោយប្រឈមមុខនឹងអន្តរឧក្រិដ្ឋកម្មជាបន្តបន្ទាប់នៅពាសពេញពិភពលោក អង្គការសហប្រជាជាតិបានបង្កើតអោយមានតុលាការអន្តរជាតិបណ្តោះអាសន្នមួយចំនួនដូចតទៅ:

១/តុលាការអន្តរជាតិសម្រាប់កាត់ទោសឧក្រិដ្ឋជនសង្គ្រាមនៅយូហ្គូស្លាវី បង្កើតនៅឆ្នាំ1993 (TPIY)

២/តុលាការអន្តរជាតិសម្រាប់កាត់ទោសឧក្រិដ្ឋជនសង្គ្រាមនៅ រ៉ាន់ដា បង្កើតនៅឆ្នាំ ១៩៩៤ (TPIR)

៣/តុលាការអន្តរជាតិសម្រាប់កាត់ទោសឧក្រិដ្ឋជនសង្គ្រាមនៅ សេរ៉ាឡេអុង, បង្កើតនៅថ្ងៃទី១៦ មករា ឆ្នាំ 2002 (TSSL)
៤/តុលាការពិសេសអន្តរជាតិសម្រាប់ លីបង់ បន្ទាប់ពីមានការធ្វើឃាតលើរូបលោក រ៉ាហ្វិក ហារីរី Rafiq Hariri,បង្កើតនៅថ្ងៃទី១៤ កុម្ភៈ ឆ្នាំ ២០០៥ តែព្រឹត្តិការណ៍នេះបណ្តាលអោយមានវិបត្តិការទូតជាខ្លាំងជាមួយនឹងប្រទេសស៊ីរី ។

## ៥/ជនជាប់ចោទទាំង១៦រូបដែលតុលាការអន្តរជាតិបានបើកនីតិក្រម

| | |
|---|---|
| **Situation en République démocratique du Congo**<br><br>**ICC-01/04-01/06**<br>***Le Procureur contre Thomas Lubanga Dyilo***<br>**ICC-01/04-01/07**<br>***Le Procureur contre Germain Katanga***<br><br>Décision relative à la jonction des affaires concernant Germain Katanga et Mathieu Ngudjolo Chui<br>Décision relative à la mise en œuvre de la norme 55 du Règlement de la Cour et de séparation des charges retenues contre les accusés<br><br>**ICC-01/04-02/06**<br>***Le*** | <br>**ICC-01/04-01/10** ***Le Procureur c Callixte Mbarushimana***<br>**ICC-01/04-01/12** ***Le Procureur c Sylvestre Mudacumura***<br>**ICC-01/04-02/12**<br><br>***Le Procureur c Mathieu Ngudjolo Chui***<br>Décision relative à la mise en œuvre des 55 du Règlement de la Cour régulation et de sectionnement des charges retenues contre les accusés<br>**Situation en République centrafricaine**<br><br>**ICC-01/05-01/08**<br>***Le Procureur contre Jean-Pierre Bemba Gombo*** |
| **Situation en Ouganda**<br><br>**ICC-02/04-01/05** ***Le Procureur c Joseph Kony, Vincer Otti, Okot Odhiambo et Dominic Ongwen***<br>**Situation au Darfour, Soudan** | <br>**ICC-02/05-02/09**<br>***Le Procureur c Bahar Idriss Abu Garda*** |



ICC-02/05-01/07 *Le Procureur c Ahmad MuhammadHarun (« Ahmad Harun ») et Ali Muhammad Ali Abd-Al-Rahman (« Ali Kushayb »)*



_ICC-02/05-01/09
*Le Procureur c Omar Hassan Ahmad Al Bashir*
© UN Photo / Stuart Price



ICC-02/05-03/09 *Le Procureur c Abdallah Banda Abkaer Nourain et Saleh Mohammed Jerbo Jamus*



ICC-02/05-01/12 *Le Procureur c Abdel Raheem Mohammed Hussein*

## Situation dans la République du Kenya



ICC-01/09-01/11 *Le Procureur c William Ruto Samoe et Joshua Arap Sang*



ICC-01/09-02/11 *Le Procureur c Francis Kirimi Muthaura et Uhuru Muigai Kenyatta*

## Situation en Libye



ICC-01/11-01/11 *Le Procureur c Saif Al-Islam Qadha et*

## Situation dans la République de Côte d'Ivoire



ICC-02/11-01/11 *Le Procureur c Laurent Gbagbo*



ICC-02/11-01/12 *Le Procureur c Simone Gbagbo*

ដូច្នេះពួកក្រុមមនុស្សឬចលនាដែលបានផ្សព្វផ្សាយអកុសលថា យកតុលាការអន្តរជាតិប្តឹង ហ៊ុនសែន នៅICCទាក់ទងនឹងឧក្រិដ្ឋកម្មខ្នាតតូចឬឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តិមុនឆ្នាំ២០០២ ដូចជាវដ្តប្រហារឆ្នាំ១៩៩៧ ឬការបោកគ្រាប់បែកនៅមុខរដ្ឋសភាឆ្នាំ១៩៩៨ ។ល។ គឺជាការបោកប្រាស់មហាជនក្នុងចេតនាអាក្រក់ណាមួយ ព្រោះឧក្រិដ្ឋកម្មទាំងនោះមិនអាចចាត់ចូលក្នុងលក្ខខណ្ឌ័របស់ ICC បានទេ ។ បុស្បា-អង្គរ

កំណត់: សូមបញ្ជាក់ថា ខ្ញុំស្រាវជ្រាវចងក្រងឯកសារនេះឡើងដោយគ្មានចេតនាអ្វីផ្សេងក្រៅពីចង់ផ្តល់ពត៌មានពិតនិងតម្លាភាពដល់សង្គមខ្មែរនៅបរទេសដែលមានភាពច្របូកច្របល់យល់ច្រឡំពីអាជ្ញាតុលាការអន្តរជាតិ ដែលស្ទើរក្លាយជាបញ្ហាសង្គមដ៏ធ្ងន់ធ្ងរ ។ ដោយខ្វះពត៌មានពិត ខ្វះការយល់ដឹងនិងខ្វះតម្លាភាព ជនរួមជាតិមួយចំនួនត្រូវទទួលការបោកប្រាស់ពីមនុស្សឬក្រុមមនុស្សខិលខូចមួយចំនួនដែលបានយកតុលាការអន្តរជាតិដើរភូតភរបោកប្រាស់ពួកគេ ។ ខ្ញុំគ្រាន់តែមានចេតនាចង់បញ្ចប់បញ្ហាសង្គមមួយដែលស្ទើរតែក្លាយជាជំបៅមហារីកសង្គមទៅហើយ ។

## ប្រភពឯកសារ

http://www.icc-cpi.int/en_menus/icc/situations%20and%20cases/Pages/situations%20and%20cases.aspx
http://www.icc-cpi.int/EN_Menus/icc/Pages/default.aspx
http://www.guardian.co.uk/law/international-criminal-court
http://www.hrw.org/topic/international-justice/lubanga-trial
http://fr.wikipedia.org/wiki/Cour_p%C3%A9nale_internationale
http://www.hrw.org/topic/international-justice/international-criminal-court
http://en.wikipedia.org/wiki/List_of_people_indicted_in_the_International_Criminal_Court

## Bibliographie


- Abdelwahab Biad, « La Cour pénale internationale à la croisée des chemins » (87-111), Annuaire Colombien de droit international, Publication de l'Universidad del Rosario (Bogota) Vol. 2, 2009.
- William Bourdon, Emmanuelle Duverger (introduit et commenté par), *La Cour pénale internationale. Le Statut de Rome*, Paris, Le Seuil, 2000 (ISBN 2-02-037194-4).
- Calvo-Goller, Karin, The Trial Proceedings of the International Criminal Court - ICTY and ICTR Precedents, Martinus Nijhoff Publishers, 2006, (ISBN 90 04 14931 7).
- Calvo-Goller, Karin, La procédure et la jurisprudence de la Cour pénale internationale, (Préface de Robert Badinter), Lextenso éditions - La Gazette du Palais, 2012 (ISBN 978-2-35971-029-8).
- Antonio Cassese, Paola Gaeta, John Jones (eds), *The Rome Statute of the International Criminal Court : A Commentary*, Oxford, Oxford University Press, 2002 (ISBN 0-19-924312-3), (ISBN 0-19-925897-X) et (ISBN 0-19-925898-8) pour chacun des trois volumes.
- Philippe Currat, *Les crimes contre l'humanité dans le Statut de la Cour pénale internationale*, Bruxelles, Bruylant, 2006 (ISBN 2-8027-2213-1) et Schulthess (ISBN 3-7255-5122-7).
- Mireille Delmas-Marty, « La Cour pénale internationale et les interactions entre droit interne et international », *Revue de science criminelle et de droit pénal comparé*, 1, 2003 (ISSN 0035-1733).
- Knut Dörmann, *Elements of War Crimes under the Rome Statute of the International Criminal Court*, Cambridge, Cambridge University Press & International Committee of the Red Cross, 2002 (ISBN 0-521-81852-4).
- Julian Fernandez, Regards croisés sur une statue de la gouvernance, Centre Thucydide, 2010
- Jean-Baptiste Jeangène Vilmer, *Réparer l'irréparable. Les réparations aux victimes devant la Cour pénale internationale*, Paris, Presses universitaires de France, 2009 (ISBN 978-2-13-057179-7).
- Roy Lee (dir.), *States' Responses to Issues Arising from the ICC Statute : Constitutional, Sovereignty, Judicial Cooperation and Criminal Law*, Ardsley, Transnational Publishers, 2005 (ISBN 15-71-05155-4).
- Xavier Philippe, Anne Desmarest, « Remarques critiques relatives au projet de loi « portant adaptation du droit pénal français à l'institution de la Cour Pénale Internationale » : la réalité française de la lutte contre l'impunité», *Revue française de droit constitutionnel*, 81, 2010(ISSN 1151-2385).